

« Neang Pi...ndap »

ARCHIVES
COTE

B-2
D-88
165

# រឿងនាងពីរជណ្ដប់ ១

B-2
D-88
N-2938

ARCHIVES NATIONALES
COTE 13-28-205 88

23-15-33
1952

កើតឡើងដោយសាលោក

ឡុងប៉េង-ជួន យន់

បានចម្លងយកមកឲ្យខ្ញុំ

ខ្ញុំក៏បានតែងទៅជាពាក្យកាព្យ

ដើម្បីឲ្យស្រួលដល់កុមារកុមារីទើបនឹងរៀនអាន

ហេតុនេះខ្ញុំសូមអភ័យទោសដល់អស់លោកជាបណ្ឌិតកវី

បើមានទៅឃើញថា ពាក្យពុំសូវប្រសើរសូមមេត្តាខន្តីអភ័យទោសដល់ខ្ញុំ

បណ្ណាគារ. គិម-អ៊ី លេខ ៨៨
វិថីអេមេក្រង់ ភ្នំពេញ

រក្សាសិទ្ធិ

ព. ស. ២៤៩៦ គ. ស. ១៩៥២

# រឿងនាងពីរដណ្ដប់

យើងនឹងដំណាលកាលពីព្រេង បុរសនេះឯងប្រពន្ធថ្មី
កាប់ឧសទៅលក់ជាប្រក្រតី ក្រស៊ើររកស៊ីបរិភោគគ្មាន ៗ
រកព្រឹកស៊ីល្ងាចជាពល់ថ្ងៃ ខំប្រឹងសើក្រយទាំងពីរប្រាណ
យប់ថ្ងៃព្រួយណាស់ដោយស្រែកឃ្លាន ពុំដែលឲ្យបានស្រួលពេលណា ៗ
ណាមួយភរិយានាងមានផ្ទៃ ពោះធំពេកក្រៃថ្លែកអស្ចារ្យ
ធំប្លែកជាងគេផងនានា ពុំងានាងប្រាប់ទៅស្វាមី ៗ
ថានែ!អ្នកបងប្អូនឈឺពោះ មាណពក៏ស្ទុះមកឃាត់ខ្ចី
នាងក៏ប្រសូត្របុត្រសុទ្ធស្រី ដប់ពីរគតបីមានប្រុសមួយ ៗ
មាណពឃើញហើយស្រែកថាអើ! កម្មអញហើយតើក្បាលវង្វួយ
ដល់ពីរដណ្ដប់គ្មានប្រុសមួយ កន្ទុំចិត្តវែងព្រួយព្រោះខ្លួនក្រ ៗ
មិនដឹងបានស៊ីមកចិញ្ចឹម ព្រោះគ្មានសន្សំមុខរបរ
បានព្រឹកខ្វះល្ងាចជួនថបរ ស៊ីទាំងត្រដសោះពាឃ្លាន ៗ
លុះកូននោះធំចេះដើរខ្ចី ទាំងប្រពន្ធប្តីតែរំខាន
ដោយរកបាយឲ្យកូនស៊ីគ្មាន ពីរប្រាណជំនុំស្រុះចិត្តគ្នា ៗ
លុះព្រឹកដល់ពេលទៅកាប់ឧស នាំកូនទៅប្រាសកន្ទអង្គា
ហើយត្រឡប់មកដល់គ្រឹហា លើកដៃសច្ចាថាគុណព្រះ ៗ
ទាំងគុណទេវតារក្សាព្រៃ ជួយកូនខ្ញុំនែឲ្យបានឈ្នះ
អស់សត្វព្រៃផងកុំបីប៉ះ កុំឲ្យប្រទះនឹងទុក្ខព្រួយ ៗ
សូមឲ្យបានសុខនឹងចំរើន នាមឈ្មោះក៏កើនដូចគេស្ទួយ

មាត់ថាចិត្តគិតរួចគេជ្រួយ ព្រោះក្បាលរង្គួយនៅក្នុងព្រៃ ៗ
កាលនោះនាងពៅជាប្អូនគេ បេះរេះគិតរកផ្លូវនៃ
នាំបងតាំងនោះដើរឃ្លាតខ្ចី ស្រៃថ្ងៃមកដល់ផ្ទះវិញណា ៗ
ឯម្ដាយឃើញហើយទ្រូងតឹងឆ្អឹស ទន្ទឹសខ្សឹកខ្សួលអួលឧក
តែទឹកថាបើទុករក្សា មុខក្ស័យជីកទាំងអស់គ្នា ៗ
លុះកន្លងទៅបានបីថ្ងៃ ឪពុកនាំវៃដើរម្លឹមា
ចូលក្នុងព្រៃជ្រៅឆ្ងាយមហិមា កូនថាឪទៅឥឆ្ងាយម៉្លេះ ៗ
មាណពថាបើកូនឯងហត់ ឪកូនកុំសត់ឈប់ត្រង់នេះ
ចាំឪចូលទៅទីរកបេះ ប្រទ្លះផ្លែឈើឲ្យកូនញុាំ ៗ
ហើយឪចូលទៅកាប់ឧសផង នេះម្ដងប្អូនកូនឯងនៅចាំ
កុំដើរទៅណាខ្លាចសត្វខាំ ចំរាំឪរកកាប់ឧសបាន ៗ
ប្រាប់ហើយចេញដើរបង្ហួសទៅ ដល់ទីលំនៅជាសុខសាន្ត
ឯកូននៅចាំត្រាំពុំបាន ព្រោះឃ្លានអាហារមុខក្រៀមផ្អែរ ៗ
តាំងពីព្រលឹមទល់ថ្ងៃត្រង់ ទាំងប្អូនទាំងបងក្រោកដើរះស្ទោះ
រកមើលផ្លែឈើក៏គ្មានសោះ ដោយស្រស់ឃ្លានណាស់ទន់អស់ប្រាណ ៗ
មួយយំថាឪអ្នកបងអើយ យើងពេលនេះហើយក្ស័យមិនខាន
នឹងចង់ទៅផ្ទះក៏ពុំបាន ព្រោះស្មានមិនត្រូវដឹងផ្លូវណា ៗ
ហើយនាំគ្នាដើរក្បាលរង្គួយ ណាព្រួយខ្លាចសត្វដំរីខ្លា
ណាអស់កម្លាំងទន់កាយា ពោះរមួលផ្សាដើរជ្រុលជ្រប់ ៗ

នាងពៅថាឱបងតាំងទ្រូ　　យើងតោងរិះរេរកទីឈប់
ប្អូនដើរមិនរួចទ្រមតាំងគ្រប់　　ខំទប់ដើរទៅទៀតពុំបាន ៗ
បងៗ អាណិតប្អូនខ្លាំងពេក　　ហូរហៀរទឹកភ្នែកស្រោចលើប្រាណ
យំព្រួទ្រហឹងក្ងស្នសាន　　ខ្លះប្រឹងអត់បានគ្រាន់តែពេប ៗ
ខ្លះថ្ងូរហ៊ឹៗ ដូចជាគ្រុន　　ខ្លះភ័យពេកពន់ស្ទុះទៅអែប
ទល់ខ្នងនឹងគេមាត់ក្រៃបែប　　ព្រោះហេតុនឹកខ្លាចសត្វព្រៃខាំ ៗ
ខ្លះថាបងអើយខ្ញុំឃ្លានណាស់　　នាងខ្លះបេះស្លឹកឈើមកញាំ
ខ្លះថាកុំយំខ្លាចសត្វខាំ　　អត់ទ្រាំទាំព្រឹកសូមទៅរក ៗ
លុះយប់នាងតាំងពីរដណ្ដប់　　ដេកលក់ស្ងាត់សព្វដោយលៃលក
ភ្លឺឡើងបងដាស់ប្អូនឲ្យក្រោក　　ទៅរកបេះផ្លែឈើគោក្ដា ៗ
នាងពីរដណ្ដប់ស្ទុះទុកសិន　　យើងនឹងនិទានពីយក្សា
មេម៉ាយអត់ប្ដីនៅកំព្រា　　ឈ្មោះនាងសន្ធមាជាស្ដេចយក្ខ ៗ
នាងមានកូនស្រីមួយនៅតូច　　ដើរពុំទាន់រួចរូបសមសក្ដិ
ខិនីទុកនៅប្រាសាទជាក់　　វិលក្សណ៍នាងចេញទៅលេងព្រៃ ៗ
ហោះចុះហោះឡើងតែម្នាក់ឯង　　កណ្ដាលឥតមានគ្នាឡើយនៃ
ទៅឃើញឯក្មេងជាច្រើនក្រៃ　　ខ៏ទីចូលទៅសួរកិច្ចកល់ ៗ
ដឹងថាក្មេងនេះគ្មានម៉ែឪ　　មកនៅកន្ទព្រៃព្រួយអំពល
ហើយបង្ហាញឲ្យមើលមណ្ឌល　　ដើម្បីនាំចូលទៅរក្សា ៤
រីឯនាងតាំងពីរដណ្ដប់　　ដឹងសព្វក៏ព្រមបរយាត្រា



ព្រោះយក្សថានាំទៅគោក្ដា　　នាងអរម្មីមានាំគ្នាទៅ　　ៗ
លុះចូលទៅដល់រាំងហើយណា　　យក្សប្រាប់បរិវាររំពេចគូវ
ឲ្យរៀបថ្វាយទឹកដោយត្រឹមត្រូវ　　ហើយប្រាប់ឲ្យនៅថែរក្សា　　ៗ
កុំឲ្យដើរទៅទីដទៃ　　ក្រែងកើតអប្រីយនាំខូចការ
ព្រោះយក្សបំរុងបរិកោក្ដា　　តែដំកាលណាស៊ីហើយនៃ　　ៗ

រីនាងតាំងពីដណ្តប់ណា    គ្មានដឹងចិន្តាយក្ខិនី
នឹកស្មានថាគេមានមេត្រី    ប្រណីករុណិតព្រោះកំព្រា    ៗ
លុះនាងចំរើនវ័យធំឡើង    ឆោមឆើតរូបល្អសមសោភា
មុខមូលក្រឡង់ដូចបទ្មា    ល្អដូច ៗ គ្មាឥតមានខ្ចោះ    ៗ
ថ្ងៃមួយខិទីចង់គោត្តា    ហើយប្រាប់សេនាឲ្យដឹងស្មោះ
ថាស្អែកនាំនាងបងបង្អស់    យកទៅខាងនោះពិឃាដខ្មី    ៗ
ថ្ងៃនពីទេត្តារក្សាបាន    ដឹងថានថ្ងៃស្អែកនាងខិទី
ពីឃាដនាងបងធ្វើបំណី    ទេវតាឃ្មាតខ្មីប្រែក្រឡា    ៗ
ធ្វើជាកណ្ដុរមួយស្អាត    សង្ខាតកាយរូងធំអស្ចារ្យ
ក្រោមកំពែងវាំងនៃយក្សា    ឲ្យនាងធីតាដើរចេញបាន    ៗ
លុះព្រឹកខិទីរៀបអាត្មា    ឡើងជិះគុជសារទៅស្មសាន
កណ្ដុរទេវតាចូលក្នុងបាន    ប្រាប់នាងកល្យាណឲ្យដឹងក្តី    ៗ
ហើយនាំនាងចេញចរយាត្រា    ពីវាំងយក្សទៅឃ្មាតខ្មី
រត់កាត់ព្រឹក្សាដោយភិតភ័យ    ទន់ជើងទន់ដៃយំរន្ធូង    ៗ
នាងហត់ខ្លាំងពេកស្រែយំថា    ឱគុណមាតាជួយខ្ញុំផង
តែយក្សមកទាន់គ្រានេះម្តង    ស្លាប់ទាំងប្អូនបងគ្មានសល់ឡើយ    ៗ
នាងបងយំថាឱកម្មខ្លួន    វេកមកជួនពុំមានស្បើយ
តាំងពីកើតមកជាតិនេះហើយ    កម្មអើយសឹងតែមានទុក្ខា    ៗ
នាងពៅថាបងកុំយំថ្វី    ខំដើរឃ្មាតខ្មីប្រញាប់ការណ៍

ក្រែងយក្សមកទាន់ចាប់អាត្មា ធ្វើជាអាហារពេលនេះនៃ ៗ
ថ្ងៃពីខិនស្រីសន្ធមា ទៅលេងព្រឹកក្សាលុះដល់ថ្ងៃ
នឹកឃ្លានអាហារវិលវិញខ្ញុំ ខិនរកនាងពីរដណ្ដប់ ៗ
ពុំឃើញគ្រវគ្រោធពិរោធក្រៃ ហៅអស់សេនីយមកសួរសព្វ
ពុំជួននាងខឹងកាយទះគប់ ស៊ើរទឹងសន្ទប់ហើយប្រើថា ៗ
ឯងនាំគ្នាទៅរកឲ្យឆាប់ ប្រញាប់វិលចូលរាជសេមា
សេនីយត្រុហើយបង្គំលា រត់ចេញម្ចម្ចាដោយភ័តភ័យ ៗ
ខ្ទះរត់ខ្ទះដើរហោះហើរព្រាត ខំប្រឹងខ្ញុំឃ្លាតគត្រូកព្រៃ
ឆ្ងាករកមើលឋានដើងស្ត្រី ខំប្រឹងឃ្លាតខ្ញុំមិនបានគិត ៗ
ដល់ក្បាលទឹងគុម្ពឈើត្រុគប់ ស៊ើរទឹងសន្ទប់ហើយភ័យភិត
ស្ពានតែគេកាយប្រឹងពិនិត្យ គ្មានមនុស្សនៅជិតរឹតភ័យខ្លាំង ៗ
នឹកខ្លាចត្រឡប់វិលអាវិញ ទុក្ខម្នោពោរមេញស្មារតីតាំង
ស៊ើរមិនហ៊ានចូលក្នុងរាជវាំង ហើយតាំងកាត់ចិត្តផ្សងតាមបុណ្យ ៗ
ដល់ហើយទុនកាយថ្វាយបង្គំ ប្រណម្យសូមទោសម្ចាស់មានបុណ្យ
ខ្ញុំរកពុំឃើញទេព្រះគុណ ខុសស៊ុនសូមទានទ្រង់មេត្តា ៗ
ឈប់ស្ទះរឿងយក្សមិនស្រដី ថ្ងៃពីស្ត្រីនោះវិញណា
នាងពីរដណ្ដប់ចរយាត្រា ដល់ជិតសេមាស្តេចមួយអង្គ ៗ
តើបតះប្រែទះស្រះមួយនៃ មានអាំងដើមជ្រៃនៅនោះផង
ទឹកសោកត្រជាក់ថ្លាក្នុង នាំអាំងអូនបងបុះមុជលេង ៗ

កញ្ច្រោកបោកបាចសាចគន្ធា
ប្រឡែងខ្សៀវខ្សារហែលទន្ទេន
បេះផ្កាព្រលិតឥតរអែង
យកមកទុកលេងដោយល្បែងស្រេ ៗ
មុជហើយនាំគ្នាឡើងរហ័ស
រួចផ្លាស់សំពត់ប្រញាប់វៃ
ខ្លះផ្លាស់រួចមុនឡើងដើមជ្រៃ
ខ្លះប្រឹងឃ្លាតខ្លីឡើងតាមគ្នា ៗ
ថ្ងៃងពីសោជ័យស្រីក្នុងកំង
ដល់ពេលហើយនាងចេញមីម្មា



ទៅរកដងទឹកស្រះវង់ថ្វា ដល់ស្រេចហើយណាចុះទៅខ្ញី ៗ
ឃើញស្រមោលនាងពីរដណ្តប់ មើលទៅសព្វៗល្អឥតបី
ស្មានថាខ្លួនឯងស្រស់ប្រិមប្រិយ ស្រីដីថាពុំគួរគេប្រើ ៗ
ឲ្យមកដងទឹកដូច្នេះណា ឯងល្អអស្ចារ្យគ្មានគេស្មើ
គួរណាសំតែស្តេចទ្រង់សរសើរ លើកឯងឲ្យធ្វើជាស្នំឯក ៗ
សៅវៃដងទឹកទៅពេញឈើចិត្ត ព្រោះគិតថាខ្លួនល្អបំផ្លែក
តាំងបោកក្អមផ្ទុនតែមិនបែក ព្រោះខឹងខ្លាំងពេកបោកត្រូវទឹក ៗ
នាងពីរដណ្តប់ដឹងសព្វគ្រប់ នាងទប់មិនបានសើចញ៉ឹក
សៅវៃងាកមើលឃើញស្ទើរភ្លឹក នាងទឹកថានេះពេញហៅល្អ ៗ
បើដូច្នេះអញទៅទូលក្សត្រថ្វៃ ប្អូសថាព្រះច័យទ្រង់ត្រេកអរ
ឲ្យនាំចូលទៅកងនគរ ភូធរតាំងធ្វើជាស្នំឯក ៗ
លុះចូលទៅដល់ថ្វាយបង្គំ ទូលព្រះបរមមិនរវែក
ថាមានស្រីល្អរូបយ៉ាងឯក ល្អប្លែកជាងស្រីផងនានា ៗ
មហាក្សត្រព្រះហើយទ្រង់ត្រេកអរ ព្រះច័យសោះសហើយសួរថា
នាងឯងបានឃើញនៅឯណា សៅវៃប្រាប់ថានៅមាត់ស្រះ ៗ
ក្សត្រាទ្រង់ព្រះព្រាក្យវាសី ចំប្រិនឃាតខ្ញីយ៉ាងរហ័ស
សេនាដើរតាមពីក្រោយប្អូស ទៅដល់មាត់ស្រះឃើញនាងល្អ ៗ
ដូចពាក្យវាសីថាប្រាកដ សាចម៉ដ្ឋមុខមូលសម្បុរស
បង្ក្រាបពន់ពៀវដូចកីណ្ណរ នេះពេញហៅល្អគួរបេតនា ៗ

ទ្រង់ត្រាស់ឲ្យហៅចុះមកដី　ហើយសួរសេចក្ដីគ្រប់ប្រការ

បានដឹងដំណើរហើយក្សត្រា　ហៅចូលសេមារំពេចខ្មី　ៗ

ទ្រង់សព្វព្រះទ័យដោយរូបល្អ　ហើយក៏តាំងនាងជាមហេសី

នៅក្នុងប្រាសាទសប្បាយក្រៃ　ស្ត្រីឥតមានព្រួយអ្វីឡើយ　ៗ

នាងពីដណ្ដប់ឈប់ស្រដី　ថ្ងៃនពីរីនោះវិញហើយ

បានដឹងដំណឹងពីត្រាណត្រើយ　ក្រេវក្រោធឥតស្បើយក្នុងចិន្ដា　ៗ

ថានាងបានធ្វើជាមហេសី　ស្ដេចគ្រង់ដែនដីធំអស្ចារ្យ

យក្សនឹកថាបើដូច្នេះណា　អញទៅមើលវាឲ្យដឹងក្ដី　ៗ

ហើយហៅកូនមកផ្ដែផ្ដាំថា　នៅមើលសេមាណាកូនស្រី

ម្ដាយទៅនគរគេឆ្ងាយក្រៃ　កូនស្រីកុំដើរទៅណាឡើយ　ៗ

ហើយផ្ដាំអស់ពួកពលសេនា　ចូរប្រយ័ត្នការកុំកន្ដើយ

មើលបុត្រីអញឲ្យល្អហើយ　កុំឲ្យវាដើរលេងផ្ដេសផ្ដាស　ៗ

ផ្ដាំស្រេចយក្សហោះចេញទៅខ្មី　ដល់ដើមព្រះដៃដែលមានស្រះ

ហើយនាងចុះទៅយ៉ាងរហ័ស　ក្លែងក្លាយបានច្បាស់រូបយ៉ាងល្អ　ៗ

ដល់ពេលរសៀលព្រះសុរិយា　អស់ពួកទាសាចេញមកស្រះ

បានឃើញយក្សក្លែងផ្អើលឈូឆរ　រត់វ៉ៃទៅទូលស្ដេចវិញខ្មី　ៗ

ថាទូលបង្គំទៅដល់ស្រះ　ឃើញស្ត្រីមួយច្បាស់ល្អឥតបី

ហាក់ដូចទេវតាឋានសួគ៌ស្រី　ល្អផុតលោកកិយរកប្រៀបគ្មាន　ៗ

នាងពីរដណ្ដប់ក៏ល្អដែរ　ប៉ុន្ដែនៅចាញ់ដោយស្នេះស្មាន

នាងឃើញក្រោះនេះពេញបំណាន ក្នុងលោកនេះគ្មានដូចនាងឡើយ ៗ
ទ្រង់បានជ្រាបហើយត្រេកអរណាស់ មានព្រះតម្រាស់ទៅថាត្រើយ
ថាឲ្យនាំមកកុំយូរឡើយ ត្រាណាត្រើយនាងល្អបែបយ៉ាងណា ៗ
តាសីឮហើយរត់ប្រញាប់ ខំប្រឹងឲ្យឆាប់មិនរេក
ដល់ហើយឱនកាយថ្វាយវន្ទា ថាព្រះរាជាមានឱង្ការ ៗ
សូមម្ចាស់ស្ត្រីទ្រង់យាងទៅ ខុសត្រូវសូមទានប្រោសមេត្តា
សន្ធមាឮហើយអរគេស្ចារ្យ បានដូចប្រាថ្នាដែលនាងប៉ង ៗ
ចុះដើរទៅតាមពួកតាសី ខិនីធ្វើបុកបែបញៀងញ៉ង
លុះដើរទៅដល់យល់ច្បាស់ច្បង់ នួនល្អង់ចូលទៅថ្វាយបង្គំ ៗ
ព្រះអង្គទ្រង់ទតយល់កាលណា ព្រះទ័យស្នេហាគួបយ៉ាងម៉ាំ
ហើយលើកតម្កើងធ្វើជាធំ ថ្នាក់ថ្នមមិនឲ្យតាស់ចិន្តា ៗ
ជាវៀងរាល់ថ្ងៃនាងសន្ធមា ប្រើទាំងអស់គ្នាឥតមេត្តា
នាងពីដណ្តប់នោះឯងណា ជីតាខំប្រឹងបំរើរ៉ា ៗ
ថ្ងៃមួយនាងធ្វើពុតជាឈឺ ដេកថ្ងូរហ៊ឺៗដោយមាយា
លុះស្តេចទ្រង់ជ្រាបទៅសួរថា នែកែវជីវ៉ានាងឈឺអ្វី ៗ
សន្ធមាឮហើយត្រេកអរណាស់ ឆ្លើយថាខ្ញុំម្ចាស់ឈឺសិរសី
នាងពីរដណ្តប់ឥតប្រណី ខ្ញុំឈឺស្ទើរក្ស័យគ្មានជួយសោះ ៗ
ខំអង្វរឲ្យជួយប្រចាប់ លោសុះមកឈ្លបឈ្លីខ្ញុំស្មោះ
ខ្វះចាប់កាច់ដៃខ្វះជាន់ពោះ ខ្វះស្ទុះមកចាប់ក្បាលទង្គិច ៗ

ខ្លះផាន់ហើយឈ្លីគ្មានមេត្តា ខ្លះគប់សិរសាខ្លះមួលមិច
ផាំពេញតាំងប្រាណខ្ញុំស្មើរផាប់ ខ្យល់មួយរំពេចព្រះគុណអើយ ៗ
មហាក្សត្រដោយត្រូវស្នេហ៍នាងយក្សព្រះទ័យស្មោះស្ម័គ្រឥតមានសៀយ
សព្វព្រះទ័យណាស់ប៉ូលកៀកកើយ ថាឱនាងអើយកុំសោកថ្វី ៗ
បងមិនទុកទោមេអបលក្សណ៍ ចិត្តវាគាក្រក់គ្មានប្រណី
ប្ដេះយកវាទៅចោលក្នុងព្រៃ កុំទុកវាថ្វីស្រីមោហោ ៗ
ថាហើយស្ដេចយាងចេញប្រញាប់ ប្រើសេនាចាប់នាំចេញចរ
យកទៅប្រាសចោលក្រៅនគរ មេយក្សត្រកអរស្លុះដើរចេញ ៗ



មកដល់ឃើញហើយប្រាប់ទៅថា នែពួកសេនាឯងស្ដាប់អញ
យកវាទៅហើយឆ្កៀលភ្នែកចេញ ទាំងអស់នេះមិញហើយដាក់ធាប់ ៗ
ទៅក្នុងអណ្ដូងមួយខាងនោះ ឲ្យវានៅរស់កុំឲ្យស្លាប់

កាលនាងសន្ធមាបញ្ចប់ផ្កាប់ ស្រេចឥតបានប្រាប់កិច្ចការណ៍សោះៗ
ថ្ងៃពីនាងទាំងពីរដណ្តាប់ ស៊ើរទឹងសន្ធប់គង់ពេលនោះ
ព្រោះគេឆ្កៀលក្អកនាងទាំងរស់ ឈើនោះវាហួសវិស័យថា ៗ
ទៅកម្មនាងទាំងពីរដណ្តាប់ នាងមានគតិគ្រប់ទាំងអស់គ្នា
នឹកថាបាបអ្វីជាតិនេះណា វេទនាកើតមកមិនដូចគេ ៗ
ណាឈើកង់ក្អែកពេកកន្ទង់ ណាឃ្លានបាយផងគ្មានទំនេរ
វេទនាពេលនេះលំបាកទ្វេរ នឹងរេមិនផុតរត់មិនបាន ៗ
ប្រសិនបើក្អែកជាទៅក៏ គ្មានទីងប្រវាត់ចេញថ្កាន
ឲ្យផុតពីដៃស្រីសាមាន្យ បើខ្វាក់គ្រប់ប្រាណរត់ម្តេចទៅ ៗ
នាងអង្គុយយំទល់មុខគ្នា រាល់ពេលវេលាទ្រូងផ្សាក្តៅ
ដោយឈើខ្ទាំងពេកមុខជាំខ្មៅ ទុក្ខព្ទលក្តៅស៊ើរទឹងក្ស័យ ៗ
ថ្ងៃពីខណ៌ស្រីសន្ធមា ផ្តាំពួកសេនាផងទីទៃ
ថាបើវាកើតកូនមកខ្ចី ចូរលៃកុំឲ្យបាយវាស៊ី ៗ
នាងយក្សផ្តាំនេះដោយបំណង ចិត្តប៉ងសម្លាប់កូនពេញទី
តែអញមិនឲ្យបាយនាងស៊ី មុខតែនារីស៊ីកូនខ្ចី ៗ
លុះកន្ទង់ទៅគ្រប់ខែដប់ នាងពីរដណ្តាប់នោះឯងនៃ
ឈើពោះប្រសូតិបុត្រមកខ្ចី ស្រ្តីឃ្លានណាស់គ្មានអ្វីស៊ី ៗ
កាលដើមឲ្យម្នាក់មួយពំនួត លុះនាងប្រសូត្រឈប់ពេញទី
ហេតុនោះនាងឃ្លានគ្មានអ្វីស៊ី នារីហែកកូនចែកគ្នាញ៉ាំ ៗ

កូនតាំងដប់មួយស៊ីតាំងអស់ ស៊ីគ្មានសល់សោះហេតុតែកម្ម
បំណែកនាងទៅនាងចេះទ្រាំ នាងខំទុកសាច់នោះតាំងអស់ ។
ដែលបងចែកឲ្យតាំងប៉ុន្មាន កល្យាណនាងគ្មានបរិភោគសោះ
ពេលនាងប្រសូត្របុត្រមកនោះ សាច់សល់តាំងអស់ចែកបងវិញ ។
បង ៗ សង្ស័យពេកអស្ចារ្យ ហើយនាងសួរថាទៅសំឡាញ់
សាច់កូនប្អូនឯងប្រសូត្រចេញ ស្អុយដូច្នេះមិញតើយ៉ាងណា ។
នាងទៅថាកូនខ្ញុំកើតមក ឆោមស្រស់ពន្លកក្បៀយដីវ៉ា
ទើបបានសាច់ស្អុយដុំខា ៗ អស្ចារ្យគឺកម្មមកពីព្រេង ។
នាង ពៅបាននៅសល់ក្អែកម្ខាង មិនសូវតេងតាងទីងគាត់តែង
គ្រាន់ថែរក្សាកូននោះឯង មិនសូវបំបែងក្នុងទ្រូងផង ។
សន្ធមាត្រថាកូនតាំងអស់ ស៊ីគ្មានសល់សេមួយជាម្ដង
នាងយក្សត្រេកអរពេកក្រន្ទង បានដូចបំណងនាងប៉ងហើយ ។
ទើបនាងស្រែកហៅកិលៀងថា ចូរហាងយាត្រាកុំកន្តើយ
កូនវ៉ាស៊ីអស់គ្មានសល់ឡើយ ហាងអើយយកបាយឲ្យវ៉ានៃ ។
តែកុំយកឲ្យវ៉ាច្រើនៈពេក បំពោះហាងចែកឲ្យដល់ដៃ
ម្នាក់មួយពន្លូតជាពល់ថៃ កុំឲ្យតែក្បែយទៅបានលើយ ។
តិចពេកឲ្យច្រើនអញដឹងច្បាស់ ហាងឯងខានពាស់ពេលនេះហើយ
សម្លាប់គ្មានទុកជីវិតឡើយ ហាងដឹងអញតើយចិត្តដូចយក្ស ។
តាសត្វហើយដើរទៅខ្ញី ឲ្យជាប្រេតគតិមិនបានសាក់

តែមួយពុំទូតកូនមួយនាក់ នាងបែកឲ្យដាក់ដាក់លំថ្ងៃ ៗ
ថ្ងៃមួយនាងពៅប្រាប់បង ៗ ថាកូនទួនល្អរស់ទេនៃ
បង ៗ ត្រូវហើយអរពេកក្រៃ ជួយលៃឲ្យនាងបាយបានឆ្អែត ៗ
ព្រោះប្អូនពៅនាងមានកូនខ្ចី បងក៏ប្រណីទៅតាមហេតុ
ឲ្យមានទឹកដោះកូនបៅឆ្អែត ហើយជួយសង្រ្កតថែតទៅ ៗ
បង ៗ ទីងនាងពៅផងនៃ លកលៃឲ្យឈ្មោះកូននោះហៅ
ថារិទ្ធិសែនយ៉ាងត្រឹមត្រូវ នាងពៅស្រឡាញ់ស្មើរជីវ៉ា ៗ
លុះកូននោះធំដឹងក្តីហើយ មិននៅកន្តើយបរយាត្រា
ចេញមកខាងក្រៅតែឯកា កុមាររិះរកមើលនាយអាយ ៗ
យល់ស្ងាត់ទើបដើរចេញដើរទៅ ឃើញក្មេងផងនៅលេងប្រញាយ
រិទ្ធិសែនចូលទៅដោយរីករាយ ខ្វល់ខ្វាយបបួលគ្នាលេងគ្នាល់ ៗ
ក្មេងៗដទៃឆ្លើយថាអើ បើដូច្នោះតើយើងក៏យល់
ព្រមតាមដាក់ស៊ូក៏មិនតាល់ ឲ្យស្គាល់យើងផ្ទាប់ឈ្នះប្រាក់រយ ៗ
រិទ្ធិសែនតបហើយឆ្លើយឡើងថា ខ្ញុំនេះណាគ្មានប្រាក់ឲ្យ
ប្រសិនខ្ញុំចាញ់ចាំថ្ងៃក្រោយ បើខ្ញុំមិនឲ្យធ្វើតាមការ ៗ
តែបើខ្ញុំឈ្នះខ្ញុំសូមបាយ តែមួយសំពាយសុំមេត្តា
តើបងព្រមគ្នាល់ប៉ុយ៉ាងណា ក្មេងនោះឆ្លើយថាអញសុខចិត្ត ៗ
បើឯងមិនសងអញៗវាយ បាយមួយសំពាយអញមិនគិត
ខ្មោចអាប៉ុណ្ណឹងអញគ្មានគិត គ្មានភ័យក្នុងចិត្តប៉ុនកូនដៃ ៗ

និយាយគ្នាស្រេចដាំអង្គុញ ចាប់លេងគ្មានធុញកណ្ដាលថ្ងៃ
លេងចាញ់រឹទ្ធិសែនតែពល់ដៃ ទឹកខឹងចង់វាយឃើញគ្នាតូច ៗ
រឹទ្ធីសែនមិនស្ដីខ្ចីតែលេង ពួកក្មេងនោះឯងមាត់ប្រចួច
ខំប្រឹងជម្រន់ក្អកម្ខាងតូច សម្រួចបោះទៅខុសទទេ ៗ
អាមួយលេងចាញ់មួយចូលទៀត រឹទ្ធីសែនខំធ្វៀតគ្មានទំនេរ
លេងឈ្នះបានបាយច្រើនយ៉ាងទ្វេ រិះរេយកទៅជូនមាតា ៗ
កុមា មកលេងផាភល់ថ្ងៃ ក្នុងវង្សនោះនៃបានសុខា
ដោយបុណ្យរឹទ្ធីសែននោះឯងណា ចិញ្ចឹមមាតាដោយសារល្បែង ៗ
លែងអត់លែងឃ្លានបានគ្រប់គ្រាន់ ថ្ងៃមួយបានមាន់បីទន្ទេង
ដើរចូលទៅក្នុងវង្សនោះឯង ពួកក្មេងវាឲ្យដោយវាចាញ់ ៗ
ថ្ងៃមួយកុមារបីដើរមក សួររកថារ៉ុយគាសុំឡាញ់
នរណាមានមាន់ជល់នឹងអញ ឈ្នះចាញ់អញចង់ជល់ក្នាល់គ្នា ៗ
អាមួយឆ្លើយឡើងថាអញមាន មាន់មួយចំណានកាត់បាវ
ជ.រមិនដែលចាញ់មាន់អ្នកណា បើជល់ឯងថាដាក់ប៉ុន្មាន ៗ
ចំណែកខាន់ទៅកុំបាច់គិត អញពិតប្រាក់មាសមិនចង់បាន
ចង់យកតែបាយបួនដប់ចាន គ្រាន់បានយកទៅស៊ីមួយថ្អែត ៗ
ក្មេងនោះព្រួហើយត្រេកអរណាស់ រត់យ៉ាងរហ័សចាប់មាន់ក្ងួត
បានហើយរត់វិលបីមាន់ថ្ដែត ចូលក្បួតដាក់មាន់ឲ្យជល់ក្បាម ៗ
ជល់មួយសន្ទុះមាន់ក្មេងចាញ់ ក្មេងនោះនឹកខ្នាញ់យំរហាម

ក្មេងខ្វះរាំចិលពេបមាត់តាម　　ខ្វះថាអាញ៉ាមអាងធ្លាប់ឈ្មុះ ។
អានោះខ្ចីនណាស់មិនចេញស្តី　　ខំរត់ឃ្មាតខ្ចីទៅដល់ផ្ទះ
ឃើញបាយក្នុងឆ្នាំងនៅច្រើនណាស់　　លើកដាក់ក្នុងកញ្ចើចាំងអស់ ។
យកមកឫទ្ធិសែនទទួលក្លាម　　មិនមានទំពាមដើរទៅស្មោះ
ដល់មាត់អណ្តូងក៏ដើបុះ　　ជូនម្តាយចាំងអស់បែកគ្នាស៊ី ។
ឫទ្ធិសែនចេញមកលេងពាល់ថ្ងៃ　　សប្បាយពេកក្រៃហើរក៏រី
ក្មេងកាន់តែច្រើនព្រួតពេញទី　　ព្រួចដល់នារីស្រីសន្ធមា ។
នាង៖អើតមក៖មើលប្រឹងពិនិត្យ　　ឃើញក្មេងមួយពិតខុសធម្មតា
រូបពង់ក៏ស្អាតគួរចេតនា　　ធីតាសួរអស់ពួកទាសី ។
គ្មាននរណាស្គាល់កូននោះសោះ　　ដោយស្រស់ប្រើអស់ពួកសេនីយ
ចូរឯងទៅតាមក្មេងនោះខ្ចី　　មើលឲ្យដឹងក្តីកូននរណា ។
សេនិយព្រួហើយរត់លឿនរីង　　ត្រង់ក្ជឹងទៅជិតទាន់កុមារ
ហើយឈប់លបមើលឲ្យដឹងការ　　ឃើញថាកុមារនោះឯងនៃ ។
ចុះក្នុងអណ្តូងដែលគេដាក់　　នាងពីរដណ្តប់ជាក់ឥតសង្ស័យ
ហើយវិលមកវិញដោយឃ្មាតខ្ចី　　ចូលទូលក្សត្រីស្រីសន្ធមា ។
នាងយក្សព្រួហើយត្រេកអរព្រួច　　គិតគួបក្នុងចិត្តបម្រុងថា
អញព្យាបាទរាំពេលនេះណា　　លុះត្រាក្សីណក្ស័យជីវិតបង់ ។
យប់នោះសន្ធមាផ្តុំពុំលក់　　ស្មារតីរវក់ព្រួយក្នុងទ្រូង
ទៀបភ្លឺទើបនឹកឧបាយផង　　ឃើញដូចបំណងដែលប្រាថ្នា ។

ព្រឹកឡើងតើនចាកពីព្រហាម　　បញ្ជាមកក្រៅហៅសេនា
ថាហើយសេនីយមកអាយក៏　　ស្ដីតអញមានការត្រូវប្រញាប់ ៗ
សេនាមកដល់យក្សប្រើថា　　ទៅហៅកុមារឲ្យយ៉ាងឆាប់
ដែលនៅក្នុងអណ្ដូងនោះស្រាប់　　ចូរទៅប្រញាប់កុំបង្អង់ ៗ
អាមាត្យរត់ទៅយ៉ាងឃ្មាតខ្មី　　ស្ទុកគន់រំពៃក្នុងអណ្ដូង
ឃើញទ្រឹសែនហើយហៅជាមួង　　មិនហ៊ានពារង់វិលវិញខ្ចី ៗ
ដល់ហើយទិនកាយថ្វាយបង្គំ　　អង្គុយសម្ងំមិនចេញស្ដី
ព្រោះខ្លាចអំណាចអង្គក្សត្រី　　គេជាមហេសីព្រះប្ញុះប្ញង ៗ
ថ្ងៃពីទិនស្រីសន្ធមា　　ឃើញអង្គកុមារអរកន្ធង
ព្រោះនឹកថាបានដូចបំណង　　ហើយនាងសាសង់ស្ដីទៅថា ៗ
ខ្ញុំឃើញអ្នកឯងរែងប្រណី　　ក្នុងពេលនេះនៃខ្ញុំមានការ
ចង់ប្រើឲ្យអ្នកចរយាត្រា　　នាំសារមួយទៅស្រុកនោះឆ្ងាយ ៗ
បើអ្នកទៅហើយបានសម្រេច　　វិលមួយរំពេចដោយសប្បាយ
អ្នកនឹងមានលាភធំដល់កាយ　　ខ្ញុំឲ្យមិនស្ដាយដោយប្រណី ៗ
ទ្រឹសែនសុខចិត្តទទួលទៅ　　ដោយនៅកុមារក្មេងសេចក្ដី
មិនហ៊ានប្រកែកខ្លាចក្សត្រី　　ក៏តក័យមិនហ៊ានតាំងងើបផង ៗ
ទ្រនីត្ដុះហើយត្រេកអរណាស់　　ថាច្បាស់ជាស្លាប់គ្រានេះមួង
ហើយប្រើអស់ពួកសេនីយផង　　ថាហង់ទៅយកគ្រឿងប្រដាប់ ៗ
ហង់យកតាំងសុរង់កឯក　　ពស្ត្រាយ៉ាងល្អមកឆាប់ៗ

កិលៀនពុំហើយសុះប្រញាប់ ទៅចាប់យកមកថ្វាក្សត្រ ៗ
ត្រៀងប្រដាប់នេះសម្រាប់ស្ដេច យ៉ាងល្អបំណាច់ផុតផែនដី
នាងយកក្បឡមកកុមារខ្ចី ក្សត្រីប្រគល់សេះមួយទៀត ៗ
សេះនេះក៏សេះសម្រាប់ស្ដេច ហើយនាងវិលគេចខំផ្ទាក់ផ្ទៀត
សរសេរសំបុត្របួរហើយសៀត កន្ស្រោមបិទជិតយកទៅខ្ចី ៗ
ចងនឹងកសេះរួតស្រួចល្អ កុមារចេញបរសំដៅព្រៃ
តែឯកអង្គព្រួយពេកក្រៃ ប្រុសថ្លៃនឹកដល់ព្រះមាតា ៗ
ជិះសេះលេចកាលចូលកន្ទៃព្រៃ សន្ធឹកសន្ធៃកន្ទកាយា
ហៀរហូរទឹកភ្នែកជោគកាយា ហើយអ្នកទ្រួញថាឱ! អ្នកម្ដាយ ៗ
ម្ដេះសមអ្នកចាំមើលផ្លូវកូន ដល់ពេលបាត់ស្ងូន្យកូនមកឆ្ងាយ
ស្មើនេះកូនធ្លាប់តែបានបាយ យកជូនអ្នកម្ដាយរាល់វេលា ៗ
ថ្ងៃនេះកូនចេញមកផុតហើយ ឱ!អ្នកម្ដាយអើយសបវេទនា
សព្វថ្ងៃបានកូនជូនអាហារ កន្លះពេលនេះណាសមអ្នកអត់ ៗ
ចាំអាហារដែលគេឲ្យនោះ បំពោះមិនគ្រប់ជាប្រាកដ
កើតមកជាតិនេះពេញកំសត់ ថែមគេពង្រាត់ឯងមកទៀត ៗ
ឱ!អ្នកម្ដាយអើយកុំតូចចិត្ត ខ្លួនខ្ញុំនេះឥតបើចង់ឃ្លាត
ដោយខ្ញុំខ្លាចអង្គព្រះមហាក្សត្រ ទើបបានខ្ញុំកាត់ចិត្តចេញមក ៗ
តែខ្ញុំទៅមិនយូរប៉ុន្មាន ប្រញាប់វិលឋានមិននៃនក
តែបានដល់ហើយកូនវិលមក រិះរកចំណីចិញ្ចឹមអ្នក ៗ

រិទ្ធិសែនជិះសេះតាំងពីព្រឹក ផាយលឿនពន្ទឹកញើសស្រាក់
ខំប្រឹងលុះដល់ថ្ងៃត្រង់ជាក់ ទើបឈប់សម្រាក់ក្រោមដើមជ្រៃ ៗ
កុមារអស់កម្លាំងខ្លាំងពេក ទើបអ្នកចូលដេកទីនោះនៃ
ឃ្លានបាយដោយអត់លុះពាល់ថ្ងៃ បាក់ពោះសន្ទៃដេកលក់ទៅ ៗ
កាលនោះមានឥសីមួយអង្គ លោកត្រេចមកត្រង់ទីនោះគួរ
ឃើញកុមារដេកទ្រង់ចូលទៅ ហើយមានសេះនៅជិតនោះផង ៗ
សេះនោះមានផ្កាក់បង់ត្រង់ក ឥសីចូលរំដោះជម្រង់
ចាប់ផ្កាកមកមើលឃើញក្រឡង់ គឺអគ្គិទីស្រីសន្ធមា ៗ
ផ្ញើទៅឲ្យនាងជាបុត្រី ឈ្មោះនាងកង្រែនោះឯងណា
សេចក្ដីសំបុត្រភជាក់ថា បើឃើញមនុស្សណាត្រូវសម្លាប់ ៗ
បើរដល់យប់សម្លាប់យប់ កុំបង្អង់ឈប់តោងកូនស្ដាប់
បើចូលដល់ថ្ងៃស្រស់បំណាច់ សម្លាប់ទាំងថ្ងៃកុំបង្អង់ ៗ
ឥស្សីទតយល់ស៊ើខ្លាចចិត្ត ព្រះទៃអាណិតស្រស់ឆោមយង់
មើលមុខស្អាតបាទពុំគួរល្ងង់ ទំនង់មិនបេះអក្សរសាស្ត្រ ៗ
បានជាយកមកគ្មានដឹងស្លាប់ មុខតែយក្សកាប់ចោលជាក់ច្បាស់
បើបេ្នះគួរអញប្រែក្រឡះ ជាក់ថាបើព្រះកុមារទៅ ៗ
ដល់ហើយបូរកូនទទួលស្មោះ យកផ្ញើប្ដីបុះណាស្រីពៅ
រៀបម្ហូបចំណីឲ្យត្រឹមត្រូវ ផាប់ផ្គុនគេទៅណាកូនស្រី ៗ
បើព្រះកុមារយាងដល់យប់ ក៏ត្រូវគោរពយកផ្ញើប្ដី

បើព្រះកុមារដល់ពេលថ្ងៃ គិតតែពីប្ដីកុំបង្អង់ ។
ឥសីសរសេរប្រែរូបហើយ បិទស្រោមកន្ទើយមិនករុង
បងនឹងក៏សេះដូចដើមហោង ហើយវិលតម្រង់ទៅសាលា ។
ថ្ងៃនឹងរិទ្ធិសែនដេកស្កប់ស្កល់ លុះដល់រសៀលព្រះសូរិយា
ក្រោកឡើងជិះសេះចេញម្នីម្នា ដោយលឿនអស្ចារ្យប្រញាប់ក្រៃ ។
ព្រោះនឹកតែម្ដាយអត់អាហារ តែយូរកាលណាខ្លាចក្រែងខ្ស័យ
ហេតុនោះទំស្រូតកាត់ព្រឹតព្រៃ លុះដល់បុរីស្រីយក្សា ។
ជិះសេះតម្រង់ទៅរកពំនគ្គ ពួកយក្សឈប្រាំងមើលកុមារ
ដោយឃើញរូបល្អបង់ស្នេហា ឈក្លុបកាយាស្មារតីកាំង ។
រិទ្ធិសែនឈប់ស្ទះមិនបរវា ថ្ងៃងពីជីតានៅក្នុងពំនគ្គ
ព្រួយចិត្តអប្រុកព្រះភ័ក្រស្ពាំង សេនាបង្ខាំងមិនឲ្យដើរ ។
ព្រោះនាងសន្ធិមារបានផ្ដាំផ្ដាច់ កុំឲ្យបរត្រាច់តាមអំពើ
ចិត្តក្មេងដែលចង់តែចេញដើរ រាមិនប្រសើរក្ដីឈ្មោះឡើយ ។
រាល់ថ្ងៃនាងលេងតែក្នុងពំនគ្គ ក៏លៀនប្រួងប្រាំងមិនកន្ទើយ
ជូនទៅសួនច្បារគ្រាន់លំហើយ បានស្បើយមិនសូវអប្រុកពេក ។
ថ្ងៃមួយរិទ្ធិសែនចូលដល់ពំនគ្គ សេនាយក្សខាំងនៅរវែក
រិទ្ធិសែនទឹងណាស់ប្រឹងជំរែក សម្រែកឮដល់ក្នុងប្រាសាទ ។
រីនាងកន្ធិសង្ស័យណាស់ ចេញមកឃើញច្បាស់រូបយ៉ាងស្អាត
មិនដឹងហេតុក៏ខំស្រឡាត មកហៅអាមាត្យទៅសួរការ ។



រិទ្ធិសែនឃើញរូបនាងកង្រី ព្រះភក្រ្តប្រិមប្រិយ៍ដូចទេវតា
ស្ទើបាត់ស្មារតីដោយស្នេហា ឈរក្ងេចកាយាស្មារតីភាំង ។
រូបចុះពីលើខ្នងសេះមក លៃលកស្រាយផ្ដាក់មកប្រឆាំង
ហើយលើកដៃក្គុំទាំងសង្ខាង គោរប់ព្រះនាងពេលនោះនៃ ។
យកផ្កាកសារៈមកបង្ហាញនាង ក៏លៀងទៅយកពានមាសខ្មី

មកទ្រព្យសារៈថ្វាយក្សត្រ ឯនាងកង្រីចូលប្រាសាទ ៗ
រិទ្ធិសែនក៏ចូលតាមនាងទៅ ដោយផ្ទៅរៀបកន្ទេលយ៉ាងស្អាត
ហើយអង្គុយទល់មុខគ្នាផ្ទាត នាងកង្រីចាត់ឲ្យអានសារៈ ៗ
អស់ពួកនាម៉ឺនអង្គុយត្រៀប ដំរៀបគ្នាប្រុងចាំស្តាប់ការ
លុះគេសូត្រចប់សេចក្តីសារ ដឹងការត្រេកអរពេកកន្ទង ៗ
រិទ្ធិសែនហើយនឹងនាងកង្រី ចាប់ចិត្តមេត្រីពេញស្នេស្នង
ពេះតែលបមើលគ្នាម្តង ៗ ដោយចិត្តចំណង់ចង់ប្រតិព័ទ្ធ ៗ
លុះសារៈសូត្រចប់នាងកង្រី ត្រេកអរពេកក្រៃស្ទើនឹងលោត
ទៅថ្វាយបង្គំស្តេចកំសត់ បិទមាត់ញញឹមមើលមុខគ្នា ៗ
ពួកពលសេនានឹងស្រីស្នំ មកថ្វាយបង្គំអគ្គក្សត្រា
ដោយបានម្ចាស់ថ្មីស្រួលសោមា ត្រេកអរគ្រប់គ្នាមិនមានទាស់ ៗ
ហើយរៀបអភិសេកនាងកង្រី នឹងរិទ្ធិសែនទ្វីសោយរាជស្មោះ
ពួកពលសេនាមកចាំងអស់ ចំពោះស៊ីលៀងគ្រប់ ៣ ថ្ងៃ ៗ
រិទ្ធិសែនឡើងពេញទីជាស្តេច យ៉ាងពិសម្រេចក្តីរាំងជ័យ
រីកកាយសប្បាយក្នុងព្រះទ័យ រកអ្វីមកប្រៀបក៏ពុំបាន ៗ
លុះថ្ងៃរសៀលនាងកង្រី នាំព្រះស្វាមីទៅកំសាន្ត
ឯក្នុងសួនច្បារទាំងពីប្រាណ កល្យាណបន្ទុលប្រាប់កន្ទង ៗ
ដែលមានស្រះស្រង់នឹងសាលា ហើយមានបុប្ផាល្អយ៉ាងខ្វង
នៅក្នុងសួននោះផ្ការីខ្ចាត់ខ្ចង យ៉ាងលេងពីរប្រាណកំសាន្តកាយ ៗ

លុះយានមកដល់ឃុំងមួយតូច ព្រះនាងនឹកព្រួយបាត់សប្បាយ
ឈរកៀបស្ពានតែមិនអាក្រាយ ធោមធាយកែណាសញ្ជ័រយាកា ៗ
រិទ្ធិសែនទឹកចូលស្ទូរទៅខ្ចី ជាឧបវណ្ណជូនដីវ៉ា
ហេតុអ្វីបានជាក្បែកាយា សូមកែវមេត្តាប្រាប់បងផង ៗ
នាងពុទ្ធិសួរទ្រង់បង្អៀត ហើយធ្លៀតឆ្លើយថាឱព្រះបង
ប្អូនភ័យខ្លាំងណាស់គ្រានេះម្តង សូមបងកុំចង់ដឹងឆ្ងើអ្វី ៗ
ព្រោះកន្ទ្រង់នេះមាតាផ្តាំ ឱ្យប្អូនថែទាំកុំស្រដី
កុំឱ្យអ្នកផងគេដឹងក្តី តែដឹងប្អូនស្រីនឹងមាតា ៗ
មុខតែព្រាត់គ្នាជាប្រាកដ បុម្មួយស្លាប់បាត់ជន្មជីវ៉ា
មិនបានសុខស្រួលដូចធម្មតា ខ្ញុំខ្លាចស្នារក្បែយចោលអ្នក ៗ
រិទ្ធិសែនពុះហើយវេតសង្ស័យ មិនដឹងមានអ្វីបានជាលាក់
កុំពុងស្រឡាញ់គ្នាឥតអាក់ នេះជាក់មានការមិនគប្បី ៗ
នាងឃើញស្វាមីឈរសំកុក បែបទ្រង់កើតទុក្ខនាងនាថភ័យ
ហើយដកកូនសោបូលទៅវៃ កន្ត្រែបំរុងនឹងបើកទ្វារ ៗ
ប៉ុន្តែដើងដៃញ័រតត្រែត កូនសោរបូតពីហត្ថា
រិទ្ធិសែនឃើញហើយមានមេត្តា ទើបថាប្អូនកំបើកឆ្ងើអ្វី ៗ
គ្រាន់តែប្រាប់បងឱ្យដឹងការណ៍ គឺថាក្នុងនោះមានរបស់អ្វី
ដោយសារកាលមាតាប្អូនស្រី ប្រាប់ក្តីសម្ងាត់បងមិននៅ ៗ
ប្រសិនបើបងនៅនោះដែរ មាតាមាសស្នេហ៍គង់ប្រាប់ផ្លូវ

ឲ្យបងបានដឹងដូចប្អូនពៅ　ហេតុនេះនោមទៅកុំលាក់ថ្វី ៗ
ទើបនាងចិតចូលនៅយ៉ាងជិត　ខ្សិបៗទាំងកិតប្រាប់ស្វាមី
ថានៅក្នុងឃ្លាំងមានតុះនៃ　ដម្កល់ពានថ្មីធ្វើពីប្រាក់ ៖
ហើយក្រឡៃមាសយ៉ាងស្អាតល្អ　ដាក់ទ្រដបថ្នាំប្រាកដ្ឋដាក់
ហើយមានក្អែកមនុស្សដប់ពីនាក់　គឺដាក់ជិតៈនោះមកយូរក្រៃ ៗ
ថ្នាំនោះបើមាននរណាធ្លាក់　គ្រាប់ក្អែកមកខ្ទាក់យូរខែថ្ងៃ
សែសទៅដាក់វិញកុំឲ្យក័ប　យកថ្នាំលាប់ខ្ទើដូចដើម ៗ
ហើយមានដំបងបញ្ចុះមន្ត　អាគុមន៍គ្រប់គ្រាន់ល្អសម្បើម
របស់មាតាខ្ញុំពីដើម　ពូកែយ៉ាងធ្នើមក្នុងវដ្ឋា ៗ
គេដាក់នៅបំកណ្ដាលតុះ　ឃាំងទុកកុំឲ្យថ្នាំនោះណា
រត់ចូលក្នុងក្អែកខូបអាសា　យកមកប្រើការពុំបានឡើយ ៗ
រិទ្ធិសែនបានស្ដាប់សព្វសេចក្ដី　ប្រាប់ក្នុងព្រះទៃអង្គត្រាណត្រើយ
ច្បាស់ជាព្រះនេត្រមាតាហើយ　ទប់ពុំបានឡើយសោយសោកា ៗ
រីនាងក្រើកភ័យកន្ទួង　សួរថាព្រះបងសូមមេត្តា
ហេតុអ្វីបានជាសោយសោកា　សូមព្រះកស្ដាទ្រង់ប្រណី ៗ
រឿងនេះខុះមកពីខ្លួនខ្ញុំ　បង្គំទូលគ្រប់សព្វសេចក្ដី
របស់ក្នុងឃ្លាំងនេះឯងនៃ　ទើបព្រះបក្រីទ្រង់សោកា ៗ
រិទ្ធិសែនខំអត្តក្ដីសោកសៅ　ហើយនាំនាងទៅលើប្រាង្គប្រា
ព្រលប់ដល់ពេលសោយក្រយ៉ា　ទ្រង់បង្អួកស្រានាងកន្ទ្រើ ៗ

ឯពួកពលយក្សទាំងអស់គ្នា រាជាបង្អកគ្មានប្រណី
ស្រវឹងខ្លាំងណាស់ទន់ជើងដៃ ឃ្លាតខ្លីទៅរកកន្លែងដេក ៗ
ដល់ហើយប្រាសខ្លួនទន់រងៀក ស្រមុកគ្រូកគ្រាក់ខ្នួរគុម្ពេក
យប់យូរស្រុនខកំពង់ដេក ស្មានតែខ្លាស្រែកប្រឹងលូលាន់ ៗ
រនាំងកក្រើកស្រវឹង ចូលផ្ទុំសន្ធឹងដូចកំពាន់
រិទ្ធិសែនឃើញហើយប្រឹងរសាក់ បន្ទាន់ចូលយកកូនសោភ្លាម ៗ
បានហើយយាងទៅឯឃ្លាំងតូច ព្រះខែសំរួចមិនទីមទៀម
ចូលដល់ចាក់សោរបើកទ្វារភ្លាម ទន្ទ្រាមដល់តុះតម្កល់ពាន ៗ
ទ្រង់យកដបថ្នាំនឹងដំបង ពានដាក់ក្នុងផង យ៉ាងខ្លាហាន
ហើយវិលចូលក្នុងប្រាសាទស្ថាន ក្បែរក្បាន្តលបៗខ្លាចនាងភ្ញាក់ ៗ
ដល់ហើយថាឱស្រស់ព្រលឹង ពេលនឹងបងសូមលារលក្ខណ៍
យប់នេះរៀមខានបានរួមក្បែរ ហើយទ្រង់បើបក្រដោយអាលៃ ៗ
ងៀកចេញទៅក្រៅបិត្តភែក ក្នុងទ្រូងស្ទើបែកស្តាយស្រីថ្លៃ
នឹកថាបើអញទៅហើយនៃ បមតែក្រោកឡើងសំសោក្កា ៗ
ប៉ុន្តែពេលនេះបើមិនទៅ មាតាលោកនូវសំទុក្ខា
ណ្ហើយចុះគូរគាត់ក្តីស្នេហា ទៅជួយមាតាឲ្យរួចទុក្ខ ៗ
បើអញស្រឡាញ់នារីរ័ត្ន៍ នឹងរាជសម្បត្តិខ្លួនបានសុខ
ឲ្យអ្នកមានគុណនៅរងទុក្ខ ឯងសុខតែឯងពុំគួរការ ៗ
ស្តេចនឹកសព្វគ្រប់ចេញទៅក្រៅ ចៅហ៊ៅទៅយកសេះ ហើយណា

ទៀងគង់លើខ្នងបរយាត្រា ក្សត្រាសំដៅទៅបុរី ៗ
លុះស្តេចទៅដល់កណ្តាលផ្លូវ មើលទៅឃើញព្រះមហាឥស្សី
ចុះពីខ្នងសេះទៅឃ្លាតខ្ចី បង្គំឥស្សីយ៉ាងគោរព ៗ
ឥស្សីទ្រង់ញាណដឹងប្រាកដ ថាកុមាររត់ចេញតាំងយប់
ពេលនាងកន្ទ្រឹមិនហ៊ានឈប់ ព្រោះអង្គចមក៏ពូទឹកមាតា ៗ
ទ្រង់មានព្រះទ័យអាណិតណាស់ ហើយត្រាស់ថានែអង្គកុមារ
ចូរអ្នកខំស្រូតទៅសេមា ធ្វើការឲ្យបានសម្រេចដាច់ ៗ
បើប្រពន្ធតាមមកទាន់ហើយ ត្រូវធ្វើប្រងើយហៅកុំស្តាប់
គោងស្រូតដំណើរឲ្យប្រញាប់ តែយូរម្តាយស្ទាប់អាសាបង់ ៗ
ហើយដំបងពេជ្រនាងសន្ធមារ ពូកែអស្ចារ្យបើបង់ធ្ងន់
ទន្ទេប្ញស្សីនៃព្រៃកំផង ក្រវីដំបងហោះធ្ងន់បាន ៗ
មួយទៀតបើប្រពន្ធនាំពល តាមមកបានយល់លំបាកប្រាណ
ទឹងតិចឲ្យផុតក្នុងស្មសាន ប្រុងប្រាណបោះមែកឈើនេះទៅ ៗ
ទឹងខាំងផ្លូវនាងតាំងអស់គ្នា កុំឲ្យវេទនាទៅតាមផ្លូវ
ឥស្សីប្រាប់ហើយទ្រង់យាងទៅ ចូលក្នុងនៃព្រៃជ្រៅតែឯកា ៗ
រិទ្ធិសែនបើងស្ទុះបង្អង់ខាន ចាប់ផ្តើមនិទានពីធីតា
ភ្ញាក់ទៀងពីព្រឹកឆាកស្រែក រាវរកក្សត្រាពុំយល់ឡើយ ៗ
ស្ទុះចេញមកក្រៅហៅកីលៀង ថានាងបានឃើញអង្គត្រាណត្រើយ
ព្រះស្វាមីអញទៅណាហើយ គោងធ្វើយប្រាប់មកឲ្យយ៉ាងដាច់ ៗ

គីលៀនឮហើយស្ទុះក្រោកខ្មី ចេញវៃមកទូលជាប្រញាប់
ថាមិនឃើញទេសូមទ្រង់ជ្រាប យប់មិញស្ងាត់ជ្រាបគ្មានឮអ្វី ។
នាងបានឮពួកគីលៀនថា មិនឃើញក្សត្រាជាស្វាមី
នាងនឹកស្ដាយណាស់ព្រោះថ្មី ៗ ហេតុអ្វីបានជាទៅមិនដឹង ។
ឯនាងក្រើប្រាប់សេនា ឲ្យប្រមូលគ្នាមកពេលហ្នឹង
ពួកយក្សគ្រាន់តែឮដំណឹង រត់ត្រង់ដើងក្ទឹងមកជុំគ្នា ។
ហើយលើកទ័ពចេញជាប្រញាប់ ដំណើរយ៉ាងឆាប់មិនរេរា
សន្ទឹកដូចក្បុះសង្រ្គា បត្តតាបាក់ខ្ទិចដោយរាំជាន់ ។
ពលយក្សប្រឹងរត់គ្មានបង្អង់ សំដៅយ៉ាងត្រង់ទ័ពមួយពាន់
កាត់កាលបួលព្រៃគ្មានធុញទ្រាន់ រត់ជាន់បាក់ខ្ទិចអស់ដើមឈើ ។
ប្រឹងស្រូតដំណើរពេញ១ថ្ងៃ ទើបទាន់ក្សត្រថ្ងៃស្រែកបណ្ដើរ
ថាឱម្ចាស់ថ្លៃរូបប្រសើរ ម្ដេចតើរត់មកចោលប្អូនស្រី ។
ព្រះបាទរិទ្ធិសេនទតឃើញច្បាស់ ភ័យណាស់ចាប់កាន់ដំបងខ្មី
ក្រវីកាលណាសេះចក្រី ហោះបើឡើងលើអាកាសា ។
ហើយទ្រង់បោះមែកឈើដែលឥ ស្សីប្រទានខ្ញីកត្រា
ព្រះធរណីស្រុតធំអស្ចារ្យ មានទាំងជល្សាហូរបុះមក ។
ទៅជាស្ទឹងមួយធំពេកក្រៃ ស្រីថ្លៃធ្ងន់មិនរួចនាងសោក
សន្ទ្រើនស្រែកហៅឲ្យបុះមក ស្រស់ធោមពន្ធកវែងខ្វាចផ្សា ។
រិទ្ធិសេនញាក់សេះវាកវិលមក ថាឱពន្ធកគូដីរ៉

សូមនាងវិលទៅកន្សោមា បងលាធីតាទៅសិនហើយ ។
នាងថាឱ! ស្វាមីសម្លាញ់ ពុំគួរឃ្លាតចេញពីប្អូនឡើយ
សមប្អូនសង្រេងពុំមានស្បើយ ម្ចាស់អើយឲ្យប្អូនសូមទៅផង ។
នាងអង្វរហើយយំក្តែងៗ កន្ទ្រងចំបែងពេកកន្ទង
រិទ្ធីសែនឃើញទ្រោះក្រៀសៅហ្មង ថាឱមាសបងកុំសោកឡើយ ។
បងទៅមិនយូរប៉ុន្មានទេ រៀមនឹងវិលមកកៀកកើយ
ពេលនេះបងសូមលាទៅហើយ គ្រាណាត្រើយកុំតាមបងទៅថ្វី ។
នាងថាបើមិនឲ្យខ្ញុំទៅ ប្អូនដើរតាមផ្លូវទាល់តែក្ស័យ
ខ្ញុំមិនវិលទេកដប្ដី ខ្លាសអស់សេនីយ សុខចិត្តស្លាប់ ។
រិទ្ធិសែនអាណិតនាងខ្លាំងណាស់ ហើយត្រាស់ថានុស្រស់ចំណាប់
នាងគិតដូច្នោះពេញពុំគាប់ ត្រូវនាំពួកទ័ពទៅប្ដី ។
ទ្រង់នឹកអាណិតបងពុះទៅ តែសេះហោះស្ទៅលឿនប្រៀវប្រែ
ពេលនោះរីឯនាងកន្រ្ទី ស្រែកហៅក្សត្រថ្ងៃយំក្តែងៗ ។
នាងតាមមើលទាល់ផុតចុងភ្នែក ទ្រង់ពុកស្ទើរបែករឹងចំបែង
ហើយប្រាប់សេនាថាអ្នកឯង ប្រឹងប្រែងរក្សាពដប្ដី ។
យើងមិនបានវិលទៅវិញទេ ត្រូវអ្នករះរេជាប្រក្រតី
មើលថែរក្សាជនប្រុសស្រី ឃ្លាតខ្ទីដូចអ្នករក្សាកូន ។
ពដការធំតូចត្រូវចងប្រាប់ មិនត្រូវបែរគេចចិត្តដោយខ្លួន
តែបែកសាមគ្គីមិនបណ្ដូន ដូចខ្លួកពាញក្បួនឡើងប្រែះសទឹក ។

នាងបុកខ្ទាំងណាស់ស្ទះម្តងៗ　　ដូចគេសំពងដោយសារទឹក
ដល់អង្គស្វាមីស្មារតីភ្ញាក　　ក្រោកខ្លួនស្ទុះលើធរណី　ៗ
នាងក្រោកប្រាសខ្លួនៈទៅទីដី　　បែកព្រះសិរសីក្ស័យជីវី
នៅជិតគល់ឈើមាត់ជលធី　　នារីក្បៀណក្ស័យអសារបង់　ៗ
ថ្ងៃងពីរិទ្ធិសែនដែលហោះទៅ　　សំដៅចូលក្នុងបុរ័គ
ដល់ហើយចូលក្នាមមិនបង្អង់　　ដម្រង់ទៅរកព្រះមាតា　ៗ
នាងទៅឃើញកូនចូលមកដល់　　បាត់ខ្វល់ហើយសួរទៅកូនថា
កូនឯងទៅបាត់ម្តាយខ្វាចផ្សារ　　តើកូនទៅណាប្រាប់ម្តាយផង　ៗ
រិទ្ធិសែនជំរាបតាមសេចក្តី　　ដែលបានស្រដីមកហើយហោង
ម្តាយឮត្រេកអរពេកកន្លង　　ទាំងម្តាយធំផងសឹងរីករាយ　ៗ
រិទ្ធិសែនយកគ្រាប់ក្នុងដាក់ឲ្យ　　ដាក់ថ្នាំបណ្តាយក្តីត្រសាយ
ដូចកាលដើមវិញៈពញសប្បាយ　　បាត់តើតក្រហាយបាត់ឈឺចាប់　ៗ
រួចហើយទ្រង់នាំមាតាទៅ　　បង្គំចមទៅជាប្រញាប់
ទូលថាបិតាសូមទ្រង់ជ្រាប　　ដោយភាពខ្លួនខ្ញុំជាពជបុត្រ　ៗ
បំណែកឯនាងសន្ធមា　　គឺវាយក្សពិតប្រាកដ
ហើយទ្រង់ដំបងចង្អុលថ្វាត់　　វររ័ត្នប្រែជាយក្ខិណី　ៗ
ស្តេចទ្រង់ទឹកឆ្ងល់ក្នុងចិន្តា　　តែគ្មានសន្ទនាតបថាអ្វី
លុះឃើញនាងយក្សខ្វាយខ្លួនខ្ញី　　ស្ទើបាត់ស្មារតីកៃម្ចាក់ឯង　ៗ
រិទ្ធិសែនវាយយក្សទឹងដំបង　　សំពងយ៉ាងខ្ទាំងឥតមានក្រែង

ចំបន្ទូលក្បាលដួលប្រចែខង ឈាមបាញ់ដូចផ្សែងហូរជាកដី ៗ
ដំបងនោះមានឫទ្ធិអស្ចារ្យ ត្រូវចំសិរសាយក្សិណី
ដួលប្រុសប្រកាច់ហាក់ដូចត្រី ក្យត្រីដាច់ខ្យល់មួយរំពេច ៗ
ទើបស្ដេចសួរព្រះកុមារថា ឯងកូនអ្នកណាហើយហេតុម្ដេច



បានជាដឹងការសព្វសារពេច ឲប្រុះសួតសាប់ប្រាប់មកប្អូន ៗ
រិទ្ធិសែនថាទូលព្រះបង្គំ ជាខ្ញុំកជបុត្រនៃនាងពៅ
ហើយទូលពីរឿងយក្សប្រើទៅ ដោយខ្ញៅបានដឹងសព្វសេចក្ដី ៗ
ទើបលួចរត់មកតែឯកា យកទាំងនេត្រាមាតាខ្ញុំ
មកបន្ទូលវិញដូចប្រក្រតី ក្សត្រថ្ងៃត្រាហើយស្មើខ្លាចចិត្ត ៗ

ហើយលោមម្ហេសីជាព្រលឹង ចូរកែវកុំខឹងណាវរមិត្រ
បងគ្មានដឹងទេរឿងនោះពិត បងគិតថាក់បំបរមង់ ៗ
ក្សត្រាអាណិតបុត្រពេកក្រៃ ជាទុះថ្ងើមថ្ងៃគ្រានេះម្ដង
បិតាឲ្យបុត្រគ្រងរាជស្នង តវង្សរៀងទៅស្រេចលើបារ ៗ
ទ្វីសែនពុំព្រមទទួលរាជ ព្រោះទ្រង់ទឹងខ្លាចមានទោសា
តែសោយរាជហើយចិត្តហានខ្វា ពុំមានរអានឹងបាបកម្ម ៗ
ហេតុនេះសូមលាព្រះបិតា បួលកង់បព្វតាផ្ញើចន្ទ្រ
ការនារក្សាទាំងសិលប្រាំ កុំរិតបងចាំសិលប្រាំបី ៗ
ស្ដេចទ្រង់ទឹកព្រួយព្រះបិត្ដា ស្មានថារាជបុត្រអន់ព្រះទៃ
ទើបទ្រង់អង្វរថាបុត្រថ្លៃ កុំទៅធ្វើអ្វីប្រុសពុំការ ៗ
ទុក្ខទោសដែលយក្សរាក់ធ្វើនោះ បំពោះវរបីឥតដឹងការណ៍
ហេតុនេះសូមបុត្រកុំក្រោធា នៅគ្រងសេមាចំនួសបួរ ៗ
ទ្វីសែនបង្គំថាសូមទោស សូមទានទ្រង់ប្រោសគ្រានេះកូវ
មេត្ដាបើកឲ្យបុត្រចេញទៅ បុត្រនឹងទ្រាំនៅពុំបានឡើយ ៗ
ក្សត្រាល្ងង់លោមបុត្រសព្វគ្រប់ ព្រះទ័យធុញថប់ពុំមានស្បើយ
ដល់នេត្រហូរដោកអង្គ្រាណាត្រើយ ទ្រង់ផ្ដើយថាឱបុត្រសម្លាញ់ ៗ
បើបានទៅហើយឲ្យបានសុខ កុំបីមានទុក្ខទ្រូងក្នុនក្នាញ់
បំណែកបិតាតែងទុក្ខមិញ ពោរពេញទៅដោយក្ដីអាល័យ ៗ
រីឯនាងទាំងពីដន្ទប់ ឱនព្រះកក្រផ្ដប់ព្រួយពេកក្រៃ

អង្វរថាឱបុត្រថ្ងើមថ្ងៃ អ្នកទៅនៅព្រៃចោលមាតា ៗ
សព្វថ្ងៃម្ដាយមានតែបារមួយ ឥតព្រួយទីពឹងស្មើដីរ៉ា
ឥឡូវបើកូនចាកសោមា សំម្ដាយខ្លោចផ្សាព្រួយចំបែង ៗ
នាងអង្វរបុត្ររ័ត្នស្នេហា ដោដល់នេត្រាសោកសង្រេង
ព្រះទៃឈឺឈួលអួលកន្ទេង ចំបែងក្នុងចិត្តឥតគណនា ៗ
រិទ្ធិសែនអង្វរព្រះមាតា តាំងព្រះបីតាពីរអង្គារ
សូមទ្រង់កុំព្រួយព្រះទ័យា ផន្ទាខ្លួនកូនពុំមែនក្ស័យ ៗ
តើកូនគ្រាន់តែចេញទៅបួស សូមមាតាប្រោះពេលនេះនៃ
កុំឲ្យកូនតឹងទ្រូងពេកក្រៃ បើពុំប្រណីកូនក្ស័យប្រាណ ៗ
នាងពីដន្ទប់ត្បូងបោះ ប្រាប់ថាទៅចុះណាយើមាន
តែក្នុងព្រះទៃរែងរុំខាន កល្យាណកាត់ចិត្តថាប្រុសថ្ងៃ ៗ
បើបាទៅបួសនៅក្នុងព្រៃ ពេលណាខ្វះអ្វីប្រកែខ
វិលមករកម្ដាយណាប្រុសថ្ងៃ ម្ដាយនឹងឃ្នាតខ្វីរកឲ្យអ្នក ៗ
រិទ្ធិសែនត្បម្ដាយព្រមឲ្យទៅ ត្រេកអរពេកក្រូវបែព្រះកក្រ
ក្រាបថ្វាយបង្គំព្រះទ្រង់ល័ក្ខ ចេញចាកដើរទៅសំដៅព្រៃ ៗ
ទៅបួសហើយសំណាក់កម្មដ្ឋាន ក្នុងព្រៃស្មសានឥតព្រួយអ្វី
រាល់ពេលវេលាតែងឃ្នាតខ្វី ដើម្បីយឲ្យបានរួចចាកទុក្ខ ៗ
ព្រះបាទរិទ្ធិសែនបួសជាសង្ឃ នៅក្នុងព្រឹកព្រៃសិងបានសុខ
សត្វព្រៃក៏គ្មានហ៊ានទើសមុខ ទ្រង់គង់ជាសុខតរៀងទៅ ៗ

នាងពីដន្ទប់នឹងក្សត្រា
នូវកូនសេមានោះឯងក្បូរ
បានសេចក្តីសុខគ្មានហ្មង់សៅ
ព្រះចៅលើកនាងធ្វើជាធំ ៗ
អស់ពួកទាសីស្រីបរិវារ
នៅថែរក្សាមួលកុះកុំ
នាងពីដន្ទប់ក៏សុខំ
ព្រោះទ្រង់នីយាំប្រោសប្រណី ៗ
ហេតុនេះទាសីសឹងកោតខ្លាច
មិនអាចធ្វើឲ្យឃ្លើសព្រះទៃ
ព្រោះខ្លាចអំណាចព្រះចក្រី
ក្សត្រីបានសុខតរៀងទៅ ៗ
រឿងនេះសន្និម៉ត់បប៉ុណ្ណេះ
ខ្ញុំពុំសូរបេះពាក្យជ្រាលជ្រៅ
រៀនតែងជំបូងទោះខុះត្រូវ
សូមមិត្តញាតិចៅកុំប្រកាន់ ៗ
ព្រោះខ្ញុំពុំមែនជាបណ្ឌិត
ឃើញរឿងនេះពិតយ៉ាងបំណាន
តែពាក្យនោះពយខ្ញុំខាន
ចង់បានជាកាព្យទើបពេញចិត្ត ៗ
ហេតុនេះខ្ញុំលើកជាកាព្យឃ្លោង
ក្នុងគ្រាជំបូងម្តងនេះពិត
បើមានខុះឆ្គងពីគំនិត
សូមលោកបណ្ឌិតជួយកែផង

ចប់

# សៀវភៅដែលមានជាវនៅគេហស្ថាន គីម-គី គឹះ

| | | |
|---|---|---|
| ច្បាប់បរឡាន . . . . | ១ សៀវភៅថ្លៃ | ១០៛០០ |
| ព្រះគោព្រះកែវ ទី ១ ដល់ទី ៧ ចប់ . | ” | ៨៛០០ |
| តេជាដំឌិន ទី ១ ដល់ទី ៧ ចប់ . . | ” | ៨៛០០ |
| ទឹកកំផ្កាកំ ទី ១ ទី ២ ចប់ . . . | ” | ៨៛០០ |
| កាព្យកំសាន្តចិត្ត . . . . | ” | ៦៛០០ |
| រឿងធន្ទមឿង ទី ១ ទី ២ ចប់ . . | ” | ៨៛០០ |
| រឿងធ្មេញជ័យ . . . . | ” | ១២៛០០ |
| រឿងអាឡាដាំងមនុស្សមាត់ទិព្វចង្កៀងទិព្វ | ” | ១៤៛០០ |
| រឿងព្រះសធន នាងកែវមនោរា ទី ១ ទី ២ ចប់ | ” | ៩៛០០ |
| រឿងសូផាត . . . . | ” | ១០៛០០ |
| ពិម្ពាពិលាប . . . . | ” | ១០៛០០ |
| នានាធម្មសំវេគ . . . . | ” | ៨៛០០ |
| ល្បើកសត្វអក . . . . | ” | ៤៛០០ |
| កុមារផ្អូន . . . . . | ” | ១០៛០០ |
| រឿងតាវឯក ទី ១ ទី ២ ទី ៣ ទី ៤ . | ” | ៤៛០០ |
| សេកសារិកា . . . . | ” | ៧៛០០ |
| រឿងរតនាវង្ស ទី ៦ ទី ៧ ទី ៨ . . | ” | ៥៛០០ |
| សុន្ទរកថា . . . . . | ” | ៥៛០០ |
| ទេវតាភាសិត . . . . | ” | ៥៛០០ |

# សៀវភៅដែលមានជាវនៅគេហស្ថាន គីម-គី គឺ:

| | | | |
|---|---|---|---|
| បកិណ្ណកបរិត | . . . . | ១ សៀវភៅថ្លៃ | ១៤៛០០ |
| វេយ្យាករណ៍បា ទី ១ | . . . | ” | ១៨៛០០ |
| ” ” ទី ២ | . . . | ” | ១៧៛០០ |
| វេយ្យាករណ៍ខ្មែរ | . . . . | ” | ១៣៛០០ |
| លេខទៀវ៍ | . . . . | ” | ១៥៛០០ |
| ធម្មសង្គហ: ភាគ ១ ភាគ ២ | . . | ” | ១៥៛០០ |
| បញ្ហាទិទ្ទេស | . . . . | ” | ២៥៛០០ |
| ប្រស្នាគិហិបដិបត្តិ | . . . . | ” | ១៨៛០០ |
| វិធីប្រែបាលី | . . . . | , | ២៥៛០០ |
| ប្រស្នាអភិធម្ម | . . . . | ” | ២៥៛០០ |
| ប្រស្នាត្រៃគុណ | . . . . | ” | ២៥៛០០ |
| សាមណេរវិន័យបញ្ហា | . . . . | ” | ២០៛០០ |

## សៀវភៅកំពុងបោះពុម្ពទៅ

រឿងដំបងក្រញូង - ភាក្រែក - បក្សីចាំក្រុង

រឿងនាងពីដណ្តប់ — រឿងចម្ប៉ាថោងចិញ្ចឹមក្រពើ

រឿងព្រះថោងនាងនាគ — រឿងព្រះបាទអជាតសត្រូវ

រឿងព្រះបទុមគោរព — រឿងជ័យសូរវង្ស

រឿងនិទានទេវទត្ត — រឿងព្រះសុវណ្ណវង្ស

នឹងសៀវភៅ បាលី-ខ្មែរ ដទៃទៀតជាច្រើន

ការផ្សាយរបស់

លេខ ៨៨ វិថីអេមេក្រង

ជិតរោងកុនព្រហ្មបាយយ័នផ្ទាល់ ភ្នំពេញ

រក្សាសិទ្ធិ

រោងពុម្ពអាស្ប៉ាទិជ
ភ្នំពេញ